**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០៧១/១៥ ក.អ.ជ.ប្រក

ថ្ងៃសុក្រ ៤ រោច ខែចេត្រ ឆ្នាំមមី ព.ស.២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា គ.ស ២០១៥

# ប្រកាស

## ស្តីពី

## ការតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការសម្រាប់គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្ម របស់គម្រោងសាងសង់ផ្លូវក្រាលកៅស៊ូប្រភេទពីរជាន់ (DBST) នៅខេត្តស្ទឹងត្រែង ក្រោមហិរញ្ញប្បទានជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីស្តង់ដារ សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងកំណត់ទូត ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៣ របស់ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** បង្កើតគណៈកម្មការកិច្ចការត្រួតពិនិត្យកិច្ចការលទ្ធកម្ម (PRC) សម្រាប់គម្រោងសាងសង់ផ្លូវក្រាលកៅស៊ូប្រភេទពីរជាន់ (DBST) នៅខេត្តស្ទឹងត្រែង ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១.ឯកឧត្តម | សួស គង់ | ប្រធាន |
| ២.ឯកឧត្តម | ចាន់ ដារ៉ុង | សមាជិក |
| ៣.លោក | បាន សុម៉ារ៉ា | សមាជិក |

៤. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២រូប សមាជិក

**ប្រការ ២**.- តែងតាំងគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃ (BEC) ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. លោក | ទូច សំណាង | ប្រធាន |
| ២. លោក | ងួន តារា | អនុប្រធាន |
| ៣. លោក | ឈា វ៉េងហ៊ុយ | សមាជិក |

**ប្រការ ៣**.- មន្ត្រីដូចមានចែងក្នុងប្រការ ១ និងប្រការ ២ មានភារកិច្ចទទួលខុសត្រូវលើការងារអនុវត្តគម្រោងផ្លូវក្រាលកៅស៊ូប្រភេទពីរជាន់ (DBST) ស្ថិតនៅខេត្តស្ទឹងត្រែង ក្រោមគម្រោងហិរញ្ញប្បទានជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន។

**ប្រការ ៤**.- សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.- នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មន្ទីរពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥
  "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ជា សុផារ៉ា

Download